ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ១១រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ ថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដោយមានសមាសភាពជំនុំជម្រះ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-លោក [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

ចៅក្រមប្រឹក្សា

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

-លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះ

សំណុំរឿងព្រហ្មទណ្ឌលេខ៣០២៤ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ ដែលមានជនជាប់ចោទ

-ឈ្មោះ [redacted] យ៉ែត ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម មុខរបរ រត់តាក់ស៊ី ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួល ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] យ៉ែន "ស" ម្តាយឈ្មោះ [redacted] ឡាញ់ "រ" ប្រពន្ធឈ្មោះ [redacted] កញ្ញា មានកូនពានាក់ ទោសពីមុន ធ្លាប់ជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

ត្រូវចោទប្រកាន់ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** និងមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីផ្តន្ទាទោសបទឧក្រិដ្ឋ ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ផ្លូវលំ ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៨៥ នៃក្រមព្រហ្មទណ្ឌ។

ណោក [redacted] មេធាវីការពារសិទ្ធិជនជាប់ចោទ។

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមលេខ ៥២០ក្រ៦"ថ"
ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១៩
-សំណុំរឿងព្រហ្មទណ្ឌលេខ ៣០២៤
ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១៧
-សំណុំរឿងស៊ើបសួរលេខ ១៨៥៩
ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៧
-សំណុំរឿងជំនុំជម្រះលេខ ៥០៥២
ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៧

អង្គហេតុនៃការចោទប្រកាន់មានដូចតទៅ

-កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ វេលាម៉ោង១៣និង២០នាទី នៅចំណុចបន្ទប់ជួល ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយមុនពេលកើតហេតុកម្លាំងសមត្ថកិច្ចនគរបាលខណ្ឌពោធិ៍សែនជ័យ បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **យ៉េត** ត្រួតពិនិត្យឆែកឆេររកឃើញក្រាមពណ៌សថ្នាំចំនួន១១កញ្ចប់ និងវត្ថុតាងមួយចំនួនទៀតនៅក្នុងបន្ទប់ចំណុចកើតហេតុខាងលើ បន្ទាប់មកសមត្ថកិច្ចក៏ធ្វើការឃាត់ខ្លួនឈ្មោះ [redacted] **យ៉េត** រួចនាំយកមកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យតែម្តង។ ក្រោយការសាកសួរឈ្មោះ [redacted] **យ៉េត** បានឆ្លើយថា ថ្នាំញៀនដែលសមត្ថកិច្ចដកហូតនោះ គឺខ្លួនទិញពីឈ្មោះ **ធី** ភេទប្រុស អាយុប្រហែល៣៧ឆ្នាំ ចំនួន៨កញ្ចប់ តម្លៃ៧,៥០០(ប្រាំពីរពាន់ប្រាំរយ)ដុល្លារអាមេរិក ហើយយកទៅលក់បន្តឱ្យម៉ូយចំណេញបានប្រហែល១,០០០(មួយពាន់)ដុល្លារអាមេរិក។

-បានឃើញរបាយការណ៍សំណោគលេខ២០៣របក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៧ របស់អធិការដ្ឋាននគរបាលខណ្ឌពោធិ៍សែនជ័យ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ៣៤៤៩អយប ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៤១៨៦ដ.ដ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

នាពេលសវនាការ

-បានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ [redacted] **យ៉េត**។

-បានស្តាប់អំណានលទ្ធផលកោសលវិច័យគ្រឿងញៀន។

-បានពិនិត្យឯកសារភស្តុតាងនានា

ការនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

-ជនជាប់ចោទឈ្មោះ [redacted] **យ៉េត** បានធ្វើការកត់សម្គាល់ថា ខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ខ្លួនដឹងកំហុសហើយ ហើយសូមតុលាការមេត្តាបន្ធូរបន្ថយទោស ហើយខ្លួនមានជំងឺប្រចាំកាយនិងកូនឈឺទៀត។

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា

តំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ៣៤៤៩អយប ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៧ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និងសុំផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

មេធាវីការពារសិទ្ធិជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា

កូនក្តីខ្លួនបានដឹងកំហុសរបស់ខ្លួនពិតមែន ហើយកូនក្តីខ្លួនបានស្នើសុំធ្វើកោសលវិច័យឡើងវិញ ដោយសារពេលទិញថ្នាំញៀនមកបានយកមកលាយសាច់ជូ ដើម្បីឱ្យបានចំណេញច្រើន នេះបញ្ជាក់ថាសារធាតុសុទ្ធនៃថ្នាំមានតិចតួច ម្យ៉ាងទៀតកូនក្តីខ្លួនបានប្តេជ្ញាកែប្រែខ្លួន កូនក្តីមានកូនតូចៗចំនួនពីនាក់ក្នុងបន្ទុកដោយកូន

ម្នាក់មានជំងឺប្រចាំកាយ ឯជនជាប់ចោទខ្លួនឯងក៏មានជំងឺប្រចាំកាយដោយមានសំបុត្រពេទ្យបញ្ជាក់ផង សូមតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីរបស់ខ្លួន។

<u>ជនជាប់ចោទបានសំណូមពរចុងក្រោយថា</u>

ជនជាប់ចោទឈ្មោះ [redacted] យ៉ែត សូមបន្ធូរបន្ថយទោសព្រោះខ្លួនដឹងខុសហើយ ខ្លួនមានជំងឺប្រចាំកាយ មានកូនតូចៗពានាក់ កូនម្នាក់ក៏មានជំងឺទៀតផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារនានាក្នុងសំណុំរឿង

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

<u>សាលាដំបូងរាជធានីភ្នំពេញ</u>

<u>យល់ឃើញថា</u>

-ជនជាប់ចោទឈ្មោះ [redacted] យ៉ែត បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ ធី ចំនួន ៨កញ្ចប់ធំ ក្នុងតម្លៃ៧,៥០០(ប្រាំពីរពាន់ប្រាំរយ)ដុល្លារអាមេរិក ពេលលក់វិញបាន ៨,៥០០(ប្រាំបីពាន់ប្រាំរយ)ដុល្លារអាមេរិក គឺចំណេញបាន ១,០០០(មួយពាន់)ដុល្លារអាមេរិក ប្រាកដមែន ខ្លួនធ្លាប់ជាប់ពន្ធនាគារចំនួន២ឆ្នាំពីបទ ជួញដូរថ្នាំញៀន ចម្លើយសារភាពនេះស៊ីសង្វាក់ទៅនឹងការចាប់យកវត្ថុតាងពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌មាន ក្រោមសច្ចាសង្ឃ័យសារជាតិញៀនចំនួន៨កញ្ចប់ធំ និង០៣កញ្ចប់តូច, ជញ្ជីងថ្លឹងថ្នាំញៀនចំនួន១, ថង់ច្រកថ្នាំញៀនចំនួន៤ដុំ, ក្រដាសវីងវេប្រាក់ចេញចំនួន១០សន្លឹក, លិខិតដោះលែងចំនួន១ច្បាប់ ដូចនេះចម្លើយសារភាពនេះត្រូវបានបញ្ជាក់ដោយភស្តុតាង។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ែត ដែលបានទិញថ្នាំញៀនពីឈ្មោះ ធី ចំនួន៨កញ្ចប់តម្លៃ ៧,៥០០(ប្រាំពីរពាន់ប្រាំរយ)ដុល្លារអាមេរិក យកទៅលក់ឱ្យម៉ូយបាន៨,៥០០(ប្រាំបីពាន់ប្រាំរយ)ដុល្លារអាមេរិក គឺចំណេញបាន១,០០០(មួយពាន់)ដុល្លារអាមេរិក នោះគឺជាអំពើទិញដើម្បីលក់នូវសារធាតុញៀន ដែលច្បាប់កំណត់ថាជាបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមលទ្ធផលកោសល្យវិច័យលេខ១០៧៨៣/១៧ម.ព.អ.ជ.ប.ត.ញ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៧ បញ្ជាក់ថាជាលទ្ធផលវិជ្ជមាន មានវត្តមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន ចំនួន៧៧,៩០% តាមលទ្ធផលនេះឃើញថា សារធាតុញៀនឈ្មោះមេតំហ្វេតាមីន ដែលជនជាប់ចោទឈ្មោះ [redacted] យ៉ែត បានជួញដូរខាងលើមានចំនួនសរុប៧៧០,៦៦ក្រាមX៧៧,៩០%=៦០០,៣៤ក្រាម ដូចនេះអំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ែត ឆ្លើយតបតាមធាតុផ្សំក្នុងបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ គឺជានីតិជនដែលមានស្មារតីដឹងខុសត្រូវគ្រប់គ្រាន់ ឃើញថា រាល់អំពើរបស់ជនជាប់ចោទរូបនេះសុទ្ធតែបានឆ្លងកាត់ការពិចារណាច្បាស់លាស់ដូចនេះជនជាប់ចោទត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់នូវអំពើរបស់ខ្លួន។

-មានភស្តុតាងធួនល្មមលើឈ្មោះ [redacted] **យ៉ែត** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ផ្លូវលំ ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១២ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៣ និងទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** ត្រូវបានចោទប្រកាន់ជាករណីមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីផ្តន្ទាទោសបទឧក្រិដ្ឋ តាមមាត្រា៨៥ នៃក្រមព្រហ្មទណ្ឌ តែពុំមានភស្តុតាងណាមួយបញ្ជាក់ថា ជនជាប់ចោទរូបនេះត្រូវបានផ្តន្ទាទោសជាស្ថាពរក្នុងបទឧក្រិដ្ឋទេ។

-យោងតាមលិខិតដោះលែងលេខ៨៩មជ/១៥ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៥ របស់មណ្ឌលអប់រំកែប្រែទី៣ បានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោសតាមសាលក្រមលេខ០២ក្រ៦ផ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៤ ដែលសម្រេចផ្តន្ទាទោសលើឈ្មោះ [redacted] **យ៉ែត** ហៅ **អួន** កំណត់២ឆ្នាំ និងពិន័យជាប្រាក់ចំនួន៤លានរៀល។ តាមកំរិតទោសនេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** បានប្រព្រឹត្តត្រឹមតែបទល្មើសមជ្ឈឹមប៉ុណ្ណោះ។

-តាមរយៈការផ្តន្ទាទោសលើជនជាប់ចោទរយៈពេល២ឆ្នាំ តាមសាលក្រមលេខ០២ក្រ៦ផ ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ២០១៤ ឃើញថា ពុំចូលក្នុងលក្ខណ្ឌនៃការមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈឹមមាត្រា៨៧ នៃក្រមព្រហ្មទណ្ឌទេ ព្រោះថាតាមមាត្រា៨៧ នៃក្រមព្រហ្មទណ្ឌនេះលុះត្រាតែបទមជ្ឈឹមនោះត្រូវបានតុលាការផ្តន្ទាទោសស្មើ ឬលើសពី៣ឆ្នាំ ទើបជាលក្ខណ្ឌនៃការបន្ថែមទម្ងន់ទោស។

-**អំពើរបស់ជនជាប់ចោទឈ្មោះ** [redacted] **យ៉ែត** ពុំចូលក្នុងលក្ខណ្ឌនៃការមិនរាងចាលតាមមាត្រា៨៥ ឬមាត្រា៨៧ នៃក្រមព្រហ្មទណ្ឌឡើយ ដូចនេះតុលាការពុំអាចបន្ថែមទម្ងន់ទោសលើជនជាប់ចោទទៅតាមខ្លឹមសារមាត្រាខាងលើនេះបានឡើយ។

-តាមការពិនិត្យលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** បានទិញថ្នាំញៀនចំនួន៨កញ្ចប់ពីឈ្មោះ **ធី** ដើម្បីយកទៅលក់បន្តឱ្យម៉ូយ ប៉ុន្តែពុំទាន់បានយកទៅលក់ផង ក៏ត្រូវឃាត់ខ្លួន ដូចនេះឃើញថាអំពើរបស់ជនជាប់ចោទខាងលើនេះពុំទាន់បង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្សនៅឡើយ។

-ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** ក្រោយពីប្រព្រឹត្តបទល្មើសបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលនិងបានសហការជាមួយសមត្ថកិច្ច និងតុលាការដើម្បីស្វែងរកឈ្មោះ **ធី** ដែលជាមេខ្លោងជួញដូរគ្រឿងញៀនតាមបុគ្គលិកលក្ខណៈ ឃើញថា ជនជាប់ចោទរូបនេះបានយល់ពីកំហុសរបស់ខ្លួនពិតប្រាកដ។

-តាមលិខិតបញ្ជាក់សុខភាពលេខ១៣៤លបល ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ របស់ផ្នែកសុខាភិបាលនៃមណ្ឌលអប់រំកែប្រែទី១ថា ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** មានជំងឺប្រចាំកាយចុកពោះ ក្អួតចង្អោ ពិបាក

រំលាយអាហារ ចុកអោយដៃជើង វិលមុខ និងកំពុងលេបថ្នាំជាប្រចាំនៅមណ្ឌលអប់រំកែប្រែទី១ តាមឯកសារពិនិត្យរបស់មន្ទីរសំរាកព្យាបាលនិងសម្ភព សុវណ្ណឌី ចោមចៅ និងឯកសារពិនិត្យរបស់បន្ទប់ពិសោធន៍អមវេជ្ជសាស្ត្រសីហា បានបញ្ជាក់ថា ឈ្មោះ **ស្រីពេជ្រ** ដែលជាកូនរបស់ជនជាប់ចោទឈ្មោះ [redacted] **យ៉ែត** ក៏មានជំងឺប្រចាំកាយផងដែរ។

-តាមរយៈកាលៈទេសៈនៃបទល្មើស បុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ និងសុខភាពរបស់ជនជាប់ចោទ ព្រមទាំងសុខភាពរបស់កូនជនជាប់ចោទថែមទៀត គប្បីតុលាការផ្តន្ទាទោសលើជនជាប់ចោទរូបនេះត្រឹមកំរិតសមល្មម។

-វត្ថុចាប់យកមាន៖ ថ្នាំញៀនចំនួន៧៦៧,៦៦ក្រាម សល់ពីការដកសំណាក ជញ្ជីងចំនួនមួយ និងឧបករណ៍កែច្នៃសម្រាប់ប្រើប្រាស់មួយចំនួន គឺជាវត្ថុមានគ្រោះថ្នាក់ដល់សុខភាពមនុស្ស និងជាវត្ថុដែលបម្រើដល់បទល្មើសផ្ទាល់ ដូចនេះត្រូវរឹបអូសតាមច្បាប់។

<u>ហេតុដូច្នេះសម្រេច</u>

១-ប្រកាសពិរុទ្ធភាពលើឈ្មោះ [redacted] **យ៉ែត** ភេទប្រុស **អាយុ៣១ឆ្នាំ** ជាតិខ្មែរ

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចបន្ទប់ជួល ផ្ទះលំ ភូមិថ្មគោល សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៣ និងទី៧ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោសលើឈ្មោះ [redacted] យ៉ែត ដាក់ពន្ធនាគារកំណត់រយៈពេល២០(ម្ភៃ)ឆ្នាំ។

៣-វត្ថុចាប់យកមាន៖ ថ្នាំញៀនមេតំហ្វេតាមីនចំនួន៧៦៧,៦៦ក្រាម សល់ពីការដកសំណាក, ជញ្ជីងសម្រាប់ថ្លឹង និងឧបករណ៍ប្រើប្រាស់ថ្នាំញៀនមួយចំនួន ត្រូវរឹបអូស។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជី	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
ហត្ថលេខា និងត្រា៖	ហត្ថលេខា និងត្រា៖	ហត្ថលេខា និងត្រា៖	ហត្ថលេខា និងត្រា៖
[redacted]			

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។"

រាជធានីភ្នំពេញ.ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]